ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
- លេខ ៥៣០ "ម"
ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។
- សំណុំរឿងព្រហ្មទណ្ឌលេខ ៥៣៦៦
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧។
- សំណុំរឿងអ៊ីបស្នរលេខ ៣៣០៨
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧។

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បើកសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ នៅសាលសវនាការទី ២ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៣៦៦ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ឆាយវ៉ាន់ ភេទប្រុស កើតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៤១ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ៣១ ផ្លូវលេខ២៨៦ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] គីមហុង មានកូន០៣ នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)
- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ២៧៣៥ "ខ១" ដ.ព.ស ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។

២. ឈ្មោះ [redacted] គីមហុង ភេទស្រី កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៤៦ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ៣១ ផ្លូវលេខ២៨៦ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] ឆាយវ៉ាន់ មានកូន០៣ នាក់ ឪពុកឈ្មោះ [redacted] យ៉ាំង (ស្លាប់) ម្តាយឈ្មោះ [redacted] ជូ (ស្លាប់) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)
- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៧៦១ "ខ១" ដ.ព.ស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨។

ត្រូវបានចោទប្រកាន់ពីបទ **រំលោភលើចំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៣ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុគន្ធាវី ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៦ ផ្លូវលេខ៦០៦ សង្កាត់ចឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- ឈ្មោះ [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
- ឈ្មោះ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

អង្គហេតុដែលត្រូវបានចោទប្រកាន់

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ឈ្មោះ [redacted] សុគន្ធារី ភេទស្រី បានខ្ចីចងការប្រាក់ពីឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង ចំនួន ៣.000.000 (ចីលាន) ដុល្លារអាមេរិក ដែលមានអត្រាការប្រាក់ចំនួន ២.៥ % (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ ហើយឈ្មោះ [redacted] សុគន្ធារី ត្រូវកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង ចំនួន ៥ កន្លែង មានដូចជា លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៤/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៥/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៦/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៤/១២ លបអវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១២ និងលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៥/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ជូនទៅឈ្មោ [redacted] អាយ វ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង ជាបណ្តោះអាសន្ន ហើយពេលឈ្មោះ [redacted] សុគន្ធារី មានប្រាក់សងគ្រប់ចំនួន ឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធ សន្យាកាត់ឈ្មោះមកឱ្យឈ្មោះ [redacted] សុគន្ធារី វិញ ដូចមានបញ្ជាក់ក្នុងលិខិតទទួលប្រាក់ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១២។ បន្ទាប់ពីទទួល បានដីធ្លី និងផ្ទះសម្បែង ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីខាងលើរួចមក បែរជាឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង យកដីខាងលើទៅផ្ទេរសិទ្ធិឱ្យឈ្មោះ [redacted] ណាគ្រី ភេទស្រី អាយុ៤៥ ឆ្នាំ និងឈ្មោះ [redacted] ពិសិដ្ឋ ភេទ ប្រុស អាយុ៣៥ ឆ្នាំ តាមលិខិតផ្ទេរសិទ្ធិលេខ ៦៨៦/១៣ លប និងលេខ ៦៨៧/ ១៣ លប ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ទៅវិញ។

- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] សុគន្ធារី។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣២០២ អ.ឃ.ញ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៣១៩៥ អ.ឃ.ញ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៤៥៤៧ "ខ១" ដ.ដ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញសាលដីកាលេខ ២២ ក្រIII (ឃ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍។
- បានឃើញសាលដីកាលេខ ៣៦១ "VI" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់តុលាការកំពូល។
- បានឃើញសាលដីកាលេខ ៥០ ក្រIII (ណ) ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍។

ដំណើរការ នៃកិច្ចពិភាក្សាដេញដោល

១. តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាយវ៉ាន់ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ចំពោះការរកស៊ីខ្ចីប្រាក់ ដាក់បញ្ចាំអចលនវត្ថុជាមួយឈ្មោះ [redacted] សុគន្ធារី គឺនៅក្នុងអំឡុងខែមេសា ឆ្នាំ២០១២។ ខ្ញុំបាទពិតជាបានប្រគល់ប្រាក់ចំនួន ៣.000. 000 (ចីលាន) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] សុគន្ធារី ប្រាកដមែន ដោយឈ្មោះ [redacted] សុគន្ធារី បានផ្ទេរសិទ្ធិដីធ្លីចំនួន ៥ (ប្រាំ) កន្លែង ឱ្យមកខ្ញុំបាទ និងប្រពន្ធខ្ញុំបាទ មានចី១ លិខិតផ្ទេរសិទ្ធិលេខ ៥៤៤/១២ លបអវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ គឺជាដីទំហំ ២០ ម៉ែត្រ គុណនឹង ៤៨ ម៉ែត្រ ស្ថិតនៅផ្លូវលេខ១២៣ ក្រុម៤ ភូមិ១ សង្កាត់ទួលទំពូងចី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ចី២ ដីទំហំ ៣០ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧២ ក្រុម៤ ភូមិ១ សង្កាត់ទួលទំពូងចី១ ខណ្ឌចំការមន រាជធានីភ្នំពេញ តាម លិខិតផ្ទេរសិទ្ធិលេខ ៥០៤ លបអវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ចី៣ ដីទំហំ ៣០ ម៉ែត្រ គុណនឹង [redacted] ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧៦ ក្រុម៣ ភូមិ១ សង្កាត់ ទួលទំពូងចី១ ខណ្ឌចំការមន រាជធានីភ្នំពេញ តាមលិខិតផ្ទេរសិទ្ធិលេខ ៥៤៥ លបអវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ចី៤ ដីទំហំ ៥៥ ម៉ែត្រ គុណនឹង ៦០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ

Scanned with CamScanner

៤៧៦ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទី៥ ដីទំហំ ១៥ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧២ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលដីលេខ ៤ និងលេខ ៥ ខ្ញុំបាទពិតជាបានផ្ទេរសិទ្ធិឱ្យទៅកូនស្រីឈ្មោះ [redacted] ណាគ្រី ប្រាកដមែន។ ការផ្ទេរសិទ្ធិដីទាំង ២ កន្លែងនេះ គឺជាចំណែកចំណូលរួមដែលមានទឹកប្រាក់ចំនួន ៣.០០០. ០០០ (បីលាន) ដុល្លារអាមេរិក ដែលឈ្មោះ [redacted] សុគន្ធារី បានខ្ចី។ ការប្តឹងខ្ញុំ និងប្រពន្ធរបស់ខ្ញុំ គឺជារឿងមិនត្រឹមត្រូវ ពីព្រោះដីទាំង អស់ឈ្មោះ [redacted] សុគន្ធារី បានផ្ទេរសិទ្ធិឱ្យមកខ្ញុំ និងប្រពន្ធរបស់ខ្ញុំរួចហើយ ដោយមានអាជ្ញាធរដឹងឮ និងប្រថាប់ត្រាទាំងអស់ ដែលដីតំបន់នោះអាជ្ញាធរមិនទាន់ធ្វើប្តង់រឹងឱ្យ ដូច្នេះខ្ញុំជាអ្នកគ្រប់គ្រងប្រើប្រាស់។ ចំពោះការផ្ទេរសិទ្ធិឱ្យទៅកូនស្រីខ្ញុំនេះ ជាលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ ព្រោះខ្ញុំ និងប្រពន្ធមានអាយុច្រើន មានជំងឺច្រើងផង។ ម្យ៉ាងទៀត ខ្ញុំមានសុខភាពមិនល្អ (មានជំងឺពាក់ព័ន្ធនឹងសរសៃប្រសាទ) និងការពារកុំឱ្យមានផលលំបាកកើតឡើងនៅពេលក្រោយ។ ប្រសិនបើឈ្មោះ [redacted] សុគន្ធារី ហៅ ឃាយក្រពើ សងប្រាក់មកខ្ញុំវិញគ្រប់ចំនួន ខ្ញុំយល់ព្រមប្រគល់ និងផ្ទេរសិទ្ធិកាន់កាប់ដីធ្លីឱ្យគាត់វិញគ្រប់ពេលវេលា។ កន្លងមកឈ្មោះ [redacted] សុគន្ធារី បានប្តឹងខ្ញុំ និងប្រពន្ធខ្ញុំម្តងរួចមកហើយ តែត្រូវតំណាងអយ្យការធ្វើការតម្កល់រឿងទុកមិនចាត់ការ តាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៦៧០ អ.ឃ.ន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣។

២. តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ចំពោះការរកស៊ីខ្ចីប្រាក់ដាក់បញ្ចាំអចលនវត្ថុជាមួយឈ្មោះ [redacted] សុគន្ធារី គឺនៅក្នុងអំឡុងខែមេសា ឆ្នាំ២០១២។ នាងខ្ញុំពិតជាបាន ប្រគល់ប្រាក់ចំនួន ៣.០០០.០០០ (បីលាន) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] សុគន្ធារី ប្រាកដមែន ដោយឈ្មោះ [redacted] សុគន្ធារី នេះបានផ្ទេរសិទ្ធិដីធ្លីចំនួន ៥ (ប្រាំ) កន្លែង ឱ្យមកនាងខ្ញុំ និងប្តី មានទី១ លិខិតផ្ទេរសិទ្ធិលេខ ៥៤៤/១២ លបអរ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ គឺជាដីទំហំ ២០ ម៉ែត្រ គុណនឹង ៤៨ ម៉ែត្រ ស្ថិតនៅផ្លូវលេខ ១២៣ ក្រុម៤ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទី២ ដីទំហំ ៣០ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧២ ក្រុម៤ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ តាមលិខិតផ្ទេរសិទ្ធិលេខ ៥០៤ លបអរ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ទី៣ ដីទំហំ ៣០ ម៉ែត្រ គុណនឹង ២៥ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧៦ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ តាមលិខិតផ្ទេរសិទ្ធិលេខ ៥៤៥ លបអរ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ទី៤ ដីទំហំ ៥៥ ម៉ែត្រ គុណនឹង ៦០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧៦ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទី៥ ដីទំហំ ១៥ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧២ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលដីលេខ ៤ និងលេខ ៥ នាងខ្ញុំពិតជាបានផ្ទេរសិទ្ធិឱ្យទៅកូនស្រីឈ្មោះ [redacted] ណាគ្រី ប្រាកដមែន។ ការផ្ទេរសិទ្ធិដីទាំង ២ កន្លែងនេះ គឺជាចំណែកចំណូលរួមដែលមានទឹកប្រាក់ចំនួន ៣.០០០.០០០ (បីលាន) ដុល្លារអាមេរិក ដែលឈ្មោះ [redacted] សុគន្ធារី បានខ្ចី។ ការប្តឹងខ្ញុំ និងប្តីរបស់ខ្ញុំ គឺជារឿងមិនត្រឹមត្រូវ ពីព្រោះដីទាំងអស់ឈ្មោះ [redacted] សុគន្ធារី បានផ្ទេរសិទ្ធិឱ្យមកខ្ញុំ និងប្តីរបស់ខ្ញុំរួចហើយ ដោយមានអាជ្ញាធរដឹងឮ និងប្រថាប់ត្រាទាំងអស់ ដែលដីតំបន់នោះ អាជ្ញាធរមិនទាន់ធ្វើប្តង់រឹងឱ្យ ដូច្នេះខ្ញុំជាអ្នកគ្រប់គ្រងប្រើប្រាស់។ ចំពោះការផ្ទេរសិទ្ធិឱ្យទៅ កូនស្រីខ្ញុំនេះ ជាលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ ព្រោះខ្ញុំ និងប្តីមានអាយុច្រើន មានជំងឺច្រើងផង។ ម្យ៉ាងទៀត ខ្ញុំមានសុខភាពមិនល្អ និងការពារកុំឱ្យមានផលលំបាកកើតឡើងនៅពេលក្រោយ។ ប្រសិនបើឈ្មោះ [redacted] សុគន្ធារី ហៅ ឃាយក្រពើ សងប្រាក់មកខ្ញុំវិញគ្រប់ចំនួន ខ្ញុំយល់ព្រមប្រគល់ និងផ្ទេរសិទ្ធិកាន់កាប់ដីធ្លីឱ្យគាត់វិញគ្រប់ពេលវេលា។ កន្លងមកឈ្មោះ [redacted] សុគន្ធារី បានប្តឹងខ្ញុំ និងប្តីខ្ញុំម្តងរួចមកហើយ តែត្រូវតំណាងអយ្យការធ្វើការតម្កល់រឿងទុកមិនចាត់ការ តាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៦៧០ អ.ឃ.ន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣។

Scanned with CamScanner

៣. តាមអំណាចឆ្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុគន្ធារី បានឆ្លើយបំភ្លឺនៅក្នុងពាក្យបណ្តឹងថា៖ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ នាងខ្ញុំបានខ្ចីចងការប្រាក់ពីឈ្មោះ [redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង ចំនួន ៣.០០០. ០០០ (បីលាន) **ដុល្លារអាមេរិក** ដែលមានអត្រាការប្រាក់ចំនួន ២.៥ % (ពីរក្បៀសប្រាំភាគរយកន្លះ) ក្នុងមួយខែ។ ការប្រាក់សរុប ៧៥.០០០ (ប្រាំពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក្នុងមួយខែ។ លោក[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង បានតម្រូវឱ្យនាងខ្ញុំកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែងចំនួន ៥ កន្លែង ដែលមាន៖ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៤/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៥/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៦/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៤/១២ លបអវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ និងលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៥/១២ លបអវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ជូនទៅពួកគាត់ជាបណ្តោះអាសន្ន ហើយភាគីលោក[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted]គីមហុង សន្យាកាត់ឈ្មោះត្រឡប់មកនាងខ្ញុំវិញនៅក្រោយពេលនាងខ្ញុំសងប្រាក់គ្រប់ចំនួនទៅគាត់វិញ។ សូមបញ្ជាក់ថា ដីទាំង៥ កន្លែងនេះ គឺមានតម្លៃប្រមាណ ២០.០០០.០០០ (ម្ភៃលាន) ដុល្លារអាមេរិក។

ក្រោយពេលខ្ចីចងការប្រាក់នេះ នាងខ្ញុំទើបតែបានបង់ការប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ជូនភាគីលោក[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង ដោយសារនាងខ្ញុំមានវិបត្តិធ្ងន់ធ្ងរ ដោយត្រូវលោក[redacted] ផុតិមា និងគូកនរំលោភយកដី ដែលមានតម្លៃជាង ៥០០.០០០.០០០ (ប្រាំរយលាន) ដុល្លារអាមេរិក នៅតំបន់ពោងពាយ ទើបភាគីនាងខ្ញុំបានសុំឱ្យភាគីលោក[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង ថែមប្រាក់ទិញដីនាងខ្ញុំខាងលើតាមតម្លៃទីផ្សារ ឬមួយសហការណ៍ ដើម្បីភាគីនាងខ្ញុំអាចយកដីខាងលើនេះទៅលក់ឱ្យអ្នកផ្សេងដើម្បីយកប្រាក់ទូទាត់សងទាំងការទាំងដើមទៅភាគីលោក [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង វិញ។ បំណងល្អរបស់ភាគីនាងខ្ញុំមិនត្រូវបានភាគីលោក[redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង យល់ព្រមឡើយ ហើយផ្ទៀតពេលដែលនាងខ្ញុំកំពុងមានវិបត្តិធ្ងន់ធ្ងរនេះ ភាគីលោក[redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង បានយកដីខាងលើទៅផ្ទេរសិទ្ធិឱ្យឈ្មោះ [redacted] ណាគ្រី ភេទស្រី អាយុ៤១ ឆ្នាំ និងឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ៣៥ ឆ្នាំ (ទាំងពីរនាក់នេះត្រូវជាកូនបង្កើតរបស់ឈ្មោះ[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង) តាមលិខិតផ្ទេរសិទ្ធិលេខ ៦៨៦/១៣ លប និងលេខ ៦៨៧/១៣ លប ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ចេញដោយចៅសង្កាត់ទួលទំពូងទី១។

អំពីឈ្មោះ[redacted] ជៀក ដែលជាចៅសង្កាត់ទួលទំពូងទី១ បានចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិមិនប្រក្រតីទាំង២ច្បាប់ កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣។ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ នាងខ្ញុំបានធ្វើលិខិតស្នើសុំមោឃភាពលិខិតផ្ទេរសិទ្ធិខុសច្បាប់ទាំង២ ដែលលោក[redacted]ជៀក បានចុះហត្ថលេខា ក៏ប៉ុន្តែលោក[redacted]ជៀក មិនត្រឹមតែមិនធ្វើតាមសំណើររបស់នាងខ្ញុំទេ គាត់ថែមទាំងណាក់បាំងលិខិតផ្ទេរសិទ្ធិទាំង២ សូម្បីតែភាគីនាងខ្ញុំស្នើសុំថតចម្លងក៏គាត់ បដិសេធដែរ។ នៅក្នុងលិខិតសុំមោឃភាព ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ នាងខ្ញុំបានរៀបរាប់អស់សេចក្តី ព្រមទាំងបង្ហាញភស្តុតាងជូនគាត់ តែគាត់នៅតែធ្វើមិនដឹង។ ទង្វើនេះអាចឱ្យនាងខ្ញុំដឹងថា ឈ្មោះ [redacted] ជៀក ពិតជាបានសមគំនិតជាមួយឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង ពិតប្រាកដមែន។ នាងខ្ញុំស្នើសុំផ្តន្ទាទោសឈ្មោះ[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង និងអ្នកសមគំនិតឈ្មោះ[redacted]ជៀក តាមច្បាប់ និងទាមទារសំណងការខូចខាតចំនួន ៣.០០០. ០០០ (បីលាន) ដុល្លារអាមេរិក។

៤. តាមអំណាចឆ្លើយរបស់សាក្សីឈ្មោះ[redacted] ជៀក បានឆ្លើយបំភ្លឺនៅចំពោះមុខតំណាងអយ្យការថា៖ ចំពោះការធ្វើផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរវាងឈ្មោះ[redacted]អាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង លើដីចំហំ ៥៥ ម៉ែត្រ គុណនឹង ៦០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧៦ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងដីចំហំ ១៥ ម៉ែត្រ គុណនឹង៥០ ម៉ែត្រ ស្ថិតនៅផ្លូវលេខ៤៧២ ក្រុម៣ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ឱ្យទៅ ឈ្មោះ [redacted] ណាគ្រី ភេទស្រី អាយុ៤១ ឆ្នាំ និងឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ៣៥ ឆ្នាំ ប្រាកដមែន។ ការផ្ទេរសិទ្ធិកាន់កាប់ខាងលើធ្វើឡើងដោយសំអាងទៅលើលិខិតផ្ទេរសិទ្ធិរវាងឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] អាយវ៉ាន់ តាមលិខិតចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ហើយរាល់ការផ្ទេរសិទ្ធិ គឺលោកអភិបាលខណ្ឌក៏បានឯកភាពចុះហត្ថលេខា ផងដែរ។ ចំពោះដីដូចក្នុងលិខិតផ្ទេរសិទ្ធិទាំង២កន្លែងខាងលើ គ្មានលិខិតស្នាម ឬដីកាសម្រេចពីតុលាការហាមឃាត់មិនឱ្យអាជ្ញាធរសង្កាត់ធ្វើការផ្ទេរសិទ្ធិឡើយ រហូតមកដល់ពេលនេះ។ ដូចអ្វីដែលខ្ញុំបាទបានបញ្ជាក់អះអាងជូនពេលនេះ គឺខ្ញុំបាទមិនបានប្រព្រឹត្តអំពើល្មើសដូចការប្តឹងចោទប្រកាន់ឡើយ។ នៅពេលដែលឈ្មោះ [redacted] សុគន្ធារី ឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង ធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ បានផ្តិតមេដៃចំពោះមុខឈ្មោះ [redacted] ជឿន ភេទប្រុស ជាសមាជិកក្រុមប្រឹក្សាសង្កាត់។ បន្ថែមពីនេះឈ្មោះ [redacted] ជឿន គឺជាសាក្សីក្នុងការធ្វើលិខិតផ្ទេរសិទ្ធិ កាន់កាប់ដីធ្លីរវាងឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង។

ខ្ញុំសូមបន្ថែមថា ពេលដែលធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ទាំងនោះ គឺខ្ញុំបាទមានតំណាងឈ្មោះ [redacted] ជឿន ក្នុងការបំពេញបែបបទលើលិខិតផ្ទេរសិទ្ធិកាន់កាប់ ដោយមានការចុះហត្ថលេខាពីប្រធានក្រុម មេភូមិ រួចរាល់ហើយទើបឈ្មោះ [redacted] ជឿន យកលិខិតទាំងនោះមកឱ្យខ្ញុំបាទចុះហត្ថលេខា។ ចំណែកលិខិតផ្ទេរសិទ្ធិទាំងនោះ ក៏មានការចុះហត្ថលេខាពីលោកអភិបាលខណ្ឌចំការមន ឈ្មោះ [redacted] ឃុយ ផងដែរ។ ចំពោះដំណើរឿងរវាងឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង គឺខ្ញុំបាទគ្រាន់តែដឹងថា ជារឿងទិញលក់ដីធ្លីតែប៉ុណ្ណោះ ហើយ ចំពោះរឿងដែលឈ្មោះ [redacted] សុគន្ធារី ថាជារឿងដាក់ដីធ្លីធ្វើការបញ្ចាំនោះ គឺខ្ញុំបានមិនបានដឹងទេ។ ចំពោះលិខិតប្រគល់ប្រាក់រវាងឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង នោះ គឺដឹងឮតែគូភាគីតែប៉ុណ្ណោះ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបាទមិនដែលបានដឹងអំពីដំណើរឿងដែរឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង សន្យាទឹងគ្នាថា ករណីដែលឈ្មោះ [redacted] សុគន្ធារី បានសងប្រាក់ទៅឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង វិញ ឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង ទឹងធ្វើការប្រគល់ដីធ្លីទាំងនោះទៅឈ្មោះ [redacted] សុគន្ធារី វិញ នោះទេ ព្រោះថា នេះជារឿងផ្ទៃក្នុងរបស់ភាគីតែប៉ុណ្ណោះ។ ចំណែកពាក្យស្នើសុំមោឃភាពលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ [redacted] សុគន្ធារី ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ វិញនោះ គឺឈ្មោះ [redacted] សុគន្ធារី ធ្វើឡើងក្រោយពេលដែលខាងសាលាសង្កាត់ទួលទំពូងទី១ និងសាលាខណ្ឌចំការមនបានចេញលិខិតផ្ទេរសិទ្ធិដែលឈ្មោះ [redacted] អាយវ៉ាន់ បានផ្ទេរទៅឱ្យឈ្មោះ [redacted] ណាគ្រី និងឈ្មោះ [redacted] ពិសិដ្ឋ តែប៉ុណ្ណោះ។ ម្យ៉ាងទៀត ពេលដែលបានទទួលពាក្យស្នើសុំមោឃភាពលិខិតផ្ទេរសិទ្ធិហើយ សាលាសង្កាត់ទួលទំពូងទី១ បានទទួលពាក្យស្នើសុំរួចរាល់ ហើយសាលាសង្កាត់បានរក្សាទុកពាក្យស្នើសុំនោះ តែមិនមានចំណាត់ការអ្វីទេ ព្រោះថាការផ្ទេរសិទ្ធិត្រូវបានធ្វើរួចរាល់អស់ហើយ។

៥. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានការពារថា ដូចដែលលោកចៅក្រមជុះនុំជម្រះបានលើកឡើងរួចមកហើយថា ករណីរឿងនេះដំបូងឡើយ គឺផ្តើមចេញពីកិច្ចសន្យាខ្ចីប្រាក ដែលកូនក្តីខ្ញុំបាទឈ្មោះ [redacted] សុគន្ធារី បានខ្ចីប្រាក់ចំនួន ៣.000. 000 (បីលាន) ដុល្លារអាមេរិក ពីជនជាប់ចោទ ដែលជាអ្នករកស៊ីចងការប្រាក់។ លក្ខខណ្ឌរបស់ជនជាប់ចោទ គឺថា ប្រសិនបើខ្ចីចងការប្រាក់ពីគាត់ ត្រូវទាមទារ ឱ្យមានរបស់ដាក់បញ្ចាំ ហើយនឹងត្រូវឱ្យផ្ទេរកម្មសិទ្ធិទៅដាក់ឈ្មោះម្ចាស់ប្រាក់ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១២ នេះ កូនក្តីរបស់ខ្ញុំបាទក៏យល់ព្រមខ្ចីប្រាក់ពីជនជាប់ចោទចំនួន ៣.000. ០00 (បីលាន) ដុល្លារអាមេរិក ដោយកូនក្តីខ្ញុំបាទព្រមច្រៀងផ្ទេរកម្មសិទ្ធិលើដីចំនួន ៥ ប័ណ្ណ ជូនទៅម្ចាស់ប្រាក់ ដែលជាជនជាប់ចោទនេះ តែការផ្ទេរកម្មសិទ្ធិលើដីចំនួន ៥ ប័ណ្ណ នេះ គឺគ្រាន់តែជាការដាក់បញ្ចាំតែប៉ុណ្ណោះ ពុំមែនជាការទិញលក់នោះទេ ដោយមានន័យយ៉ាងច្បាស់នៅក្នុងកិច្ចសន្យា ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២។ ពេលដែលភាគីអ្នកខ្ចី ប្រាក់ឈ្មោះ [redacted] សុគន្ធារី មានលទ្ធភាពសងប្រាក់វិញ ឈ្មោះ [redacted] អាយវ៉ាន់ និងប្រពន្ធឈ្មោះ

[redacted] គីមហុង ត្រូវ ធ្វើការផ្ទេរកម្មសិទ្ធលើដីចំនួន ៥ ប័ណ្ណ នោះឈ្មោះ [redacted] សុគន្ធារី វិញ ពីព្រោះទ្រព្យនេះ គឺជាទ្រព្យដាក់បញ្ចាំ។ បន្ទាប់ពីកូនក្តីខ្ញុំបាទឈ្មោះ [redacted] សុគន្ធារី បានផ្ទេរកម្មសិទ្ធិឱ្យឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង រួច ឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted]គីមហុង បានលួចផ្ទេរកម្មសិទ្ធិដីចំនួន ២ ប័ណ្ណ ទៅឱ្យកូនរបស់គាត់ឈ្មោះ[redacted]ណាត្រី និងឈ្មោះ[redacted] ពិសិដ្ឋ ដោយមិនបានឱ្យកូនក្តីខ្ញុំបាទបានដឹងនោះទេ។ បន្ទាប់ពីបានដឹងរឿងនេះ កូនក្តីខ្ញុំបាទក៏បានទៅដាក់ពាក្យសុំដីកាសម្រេចរក្សាការពារដីចំនួន ៣ ប័ណ្ណ ដែលនៅសល់។ ដូច្នេះហើយបានជាកូនក្តីខ្ញុំបាទ ហ៊ានដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងរាជធានីភ្នំពេញ រហូតដល់ទៅក្រមស៊ើបសួរ តែនៅពេលនោះទៅក្រមស៊ើបសួរក៏បានសម្រេចលើកលែងចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង តែដោយកូនក្តីខ្ញុំបាទមិនសុខចិត្តក៏បានប្តឹងទៅសាលាឧទ្ធរណ៍ ពីព្រោះក្នុងរឿងនេះ ជនជាប់ចោទបានលួចយកដីដែល បានដាក់បញ្ចាំចំនួន ២ ប័ណ្ណ ទៅផ្ទេរសិទ្ធិឱ្យកូនបាត់ទៅហើយ ដោយចម្លើយរបស់គាត់នៅទៅក្រមស៊ើបសួរ គាត់បានឆ្លើយថា ដោយសារតែគាត់មានវ័យចាស់ជរា មានជំងឺច្រើន និងខ្លាចពិបាកទៅថ្ងៃក្រោយ ទើបគាត់ផ្ទេរទៅឱ្យកូន របស់គាត់ តែចម្លើយនេះ គឺមិនសមហេតុផលនោះឡើយ។ នៅពេលដែលកូនក្តីខ្ញុំបាទប្តឹងឧទ្ធរណ៍ ហើយត្រូវបាន សាលាឧទ្ធរណ៍តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់របស់សាលាដំបូងរាជធានីភ្នំពេញ។ ក្រោយមកទៀតកូនក្តី ខ្ញុំបាទក៏បានដាក់ពាក្យបណ្តឹងទៅតុលាការកំពូលទៀត ហើយត្រូវបានតុលាការកំពូលយល់ឃើញថា សំអាងហេតុលើកលែងចោទប្រកាន់របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ពុំមានហេតុផលសមស្រប ពុំមានទំនាក់ទំនងគតិយុត្តដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង មានចេតនាត្រឹមត្រូវនោះទេ គឺបានន័យថា គេរកឃើញគាត់ទាំងពីរនាក់មានចេតនាទុច្ចរិត ដូចនេះ ហើយទើបក្រុមប្រឹក្សាជំនុំជម្រះ តុលាការកំពូល បានចេញសាលដីកាលេខ ៣៦១ "VI" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ សម្រេចលុបចោលសាលដីការបស់សាលាឧទ្ធរណ៍លេខ ២២ ក្រIII (ឃ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ដូច្នេះ ឃើញថា តុលាការកំពូល យល់ឃើញថា ការលើកលែងចោទប្រកាន់លើជនជាប់ចោទ មិនត្រូវនោះទេ ទើបតុលាការកំពូលសម្រេចឱ្យសាលា ឧទ្ធរណ៍ធ្វើការជំនុំជម្រះសាជាថ្មី ដោយបានសម្រេចបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៤៥៤៧ "ខ១" ដ.ដ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់ទៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចោលជាអាសាបង់ និងចោទប្រកាន់លើឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង ដោយបង្វិលសំណុំរឿងនេះនេះមកសាលាដំបូង រាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះ។ ខ្ញុំបាទទើបតែទទួលបានខ្លះភស្តុតាងមួយទៀត នៅពេលដែលកូនក្តីខ្ញុំបាទ ដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ហើយនៅពេលដែលធ្វើការផ្ទុកផ្តាក់ទៅច្រកចេញចូលតែមួយ ពេលនោះខាងមន្ទីរៀបចំដែនដី រាជធានីភ្នំពេញ បានចេញលិខិតមួយថា ក្នុងចំណោមដីទាំង ៣ ប័ណ្ណនេះ គឺមានមួយប័ណ្ណត្រូវបាន ឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted]គីមហុង ផ្ទេរកម្មសិទ្ធិឱ្យឈ្មោះ [redacted]ខេង និងឈ្មោះ[redacted] ណាវី។ ដូច្នេះ ចំពោះដីទាំង ៥ ប័ណ្ណ ដែលកូនក្តីខ្ញុំបាទដាក់បញ្ចាំនោះ គឺឥឡូវនៅសល់តែចំនួន ២ ប័ណ្ណតែប៉ុណ្ណោះ ដែលមានឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted]គីមហុង។ ដូចនេះ ឃើញថា ចេតនារបស់ឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] គីមហុង បានធ្វើនេះ គឺវាពិតណាស់ដែលទាក់ទងទៅនឹងនិយមន័យនៃបទរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយនាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណាត់។ ចំណុចនេះ ប្រសិនបើជនជាប់ចោទមានចេតនាត្រឹមត្រូវមែននោះ គឺត្រូវធ្វើការជូនដំណឹងដល់កូនក្តីខ្ញុំបាទដែលជាម្ចាស់ តែនេះកូនក្តីក្តីខ្ញុំបាទមិនបានដឹងនោះទេ នេះសបញ្ជាក់ថា គាត់មានចេតនាទុច្ចរិត តែតុលាការកំពូល ក៏ដូចជាសាលាឧទ្ធរណ៍ រកឃើញថា ជាបទល្មើសរំលោភលើទំនុកចិត្ត ទើបបញ្ជូនរឿងនេះមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះ ពីបទ រំលោភលើទំនុកចិត្ត។ ដូច្នេះ ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សុគន្ធារី ស្នើសុំលោកចៅក្រមសម្រេច ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]ឆាយវ៉ាន់ និងប្រពន្ធឈ្មោះ[redacted] គីមហុង ទៅតាមបទចោទ ដែលសាលាឧទ្ធរណ៍បញ្ជូនមកសាលាដំបូង

រាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះនេះ ព្រមទាំងស្នើសុំសំណងរដ្ឋប្បវេណីចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៦. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ តំណាងអយ្យការស្នើសុំឱ្យចៅក្រមជំនុំជម្រះពិនិត្យមើលលើភស្តុតាង និងសេចក្តីសម្រេចរបស់តុលាការកំពូល ក៏ដូចជាសេចក្តីសម្រេចរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ និងស្នើសុំឱ្យតុលាការសម្រេចទៅតាមច្បាប់។

៧. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ចំពោះចំណុចវិវាទសំខាន់ គឺត្រង់ថា លិខិតទទួលប្រាក់នេះ តើច្បាប់ទទួលស្គាល់ជាចរិតបែបការអាក់បញ្ចាំស្របតាមបញ្ញត្តិមាត្រា៨១៦ និងមាត្រា៨២០ នៃក្រមរដ្ឋប្បវេណី ឬមួយជាការលក់ទិញស្របតាមបញ្ញត្តិមាត្រា ៥១៥ និងមាត្រា៥១៦ នៃក្រមរដ្ឋប្បវេណី។ ខ្ញុំបាទយល់ឃើញថា ចំពោះលិខិតនេះ គឺមានចរិតលក់ទិញ ពីព្រោះប្រសិនបើជាលក្ខណៈអាក់បញ្ចាំ គឺមិនមានតម្រូវជាលិខិតផ្ទេរកម្មសិទ្ធិនោះទេ ហើយការចូលរួមផ្ទេរកម្មសិទ្ធិនេះទៀត គឺធ្វើឡើងដោយលិខិត ឃថាភូត ដោយមានការចូលរួមពីប្រធានក្រុម មេភូមិ ចៅសង្កាត់ និងសាលាខណ្ឌដូច្នេះ នេះបញ្ជាក់ឱ្យឃើញថា នេះមិនមែនជាការអាក់បញ្ចាំ ដូចលោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនោះទេ គឺជាការលក់ទិញ តែប្រសិនបើគាត់ចង់លោះទៅវិញ គាត់ត្រូវតែធ្វើការបង់ប្រាក់ដើម និងការប្រាក់ ស្របតាមបញ្ញត្តិមាត្រា ៥៦៣ នៃក្រមរដ្ឋប្បវេណី ហើយមួយទៀតខ្ញុំបាទក៏សូមបញ្ជាក់ថា តាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងនិយមន័យនៃបទល្មើសរំលោភលើទំនុកចិត្ត ដែលលោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងត្រង់ចំណុចយល់ព្រមមានភារកិច្ចប្រគល់សងមកវិញ ដោយចំណុចនេះឃើញថាប្រគល់សងទាំងប្រាក់ដើម និងការប្រាក់ តែគាត់មិនបានសងនោះទេ តែបែរជាមកប្តឹងកូនក្តីខ្ញុំបាទពីបទរំលោភលើទំនុកចិត្តទៅវិញ ចំណុចនេះប្រសិនបើកូនក្តីខ្ញុំបាទធ្វើការផ្ទេរកម្មសិទ្ធិទាំង ៥ ប័ណ្ណ ក៏មិនសុខនោះដែរ ពីព្រោះនេះមិនមែនជាចរិតលក្ខណៈនៃការបញ្ចាំនោះទេ។ ខ្ញុំបាទយល់ឃើញថា ចំពោះលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ គឺជាការលក់ទិញ ដោយអនុវត្តការលក់ ស្របតាមបញ្ញត្តិមាត្រា ៥១៥ មាត្រា ៥១៦ និងមាត្រា ៥៦៣ នៃក្រមរដ្ឋប្បវេណី។

ចំពោះលិខិតដែលលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ជាការអាក់បញ្ចាំនោះ ខ្ញុំបាទយល់ឃើញថា ប្រសិនបើជាការអាក់បញ្ចាំគឺមានកំណត់ទុរកាលបរិច្ឆេទ តែនេះមិនមាននោះទេ។ ដូច្នេះ ការផ្ទេរដីមកឱ្យកូននេះប្រសិនបើគិតអំពីលំហូរនៃក្រមនីតិវិធីរដ្ឋប្បវេណី គឺការផ្ទេរទ្រព្យពីឪពុកម្តាយទៅកូនជាបទល្មើសដែរឬទេ? ដូចនេះនៅក្នុងស្ថានភាពមួយដែលគាត់ថាជាការអាក់បញ្ចាំ តើមានចំណុចណាមួយដែលលោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកពីចំណុចនេះថា គាត់ត្រូវតែមានកាតព្វកិច្ចប្រគល់ឱ្យនៅពេលដែលគាត់មានប្រាក់សង។ ដូច្នេះ ប្រសិនបើពិនិត្យមើលទៅលើភាគីដែលមិនបានអនុវត្តកាតព្វកិច្ច លោកស្រី [redacted] សុគន្ធារី ក្រោយពីផ្ទេរចប់ គឺគាត់បាត់ខ្លួនរហូតមកដល់ពេលនេះ ហើយគាត់ក៏មិនដែលបានចូលមកបំពេញកាតព្វកិច្ចជូនកូនក្តីខ្ញុំបាទនោះដែរ។ ទាក់ទងទៅនឹងការលើកឡើងរបស់លោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងរឿងរក្សាការពារនៅក្នុងរឿងនេះក៏មិនមាននោះដែរ ហើយគាត់ក៏មិនដែលមានប្តឹងសុំអនុវត្តកាតព្វកិច្ចរបស់គាត់នោះដែរ។ ដូច្នេះប្រសិនបើនិយាយពីអាជ្ញាយុកាលនៃកិច្ចសន្យានេះ ក៏ត្រូវបានផុតរលត់បាត់ទៅហើយ ផ្អែកតាមក្រមរដ្ឋប្បវេណី គឺការអនុវត្តកិច្ចសន្យាសិទ្ធិលក់ ត្រូវបានរលត់បាត់ហើយ គឺរយៈពេល៥ ឆ្នាំ។ រហូតមកដល់ពេលនេះ គឺលោកស្រី [redacted] សុគន្ធារី មិនដែលចេញមុខមកសួរកូនក្តីខ្ញុំបាទ ដើម្បីសុំអនុវត្តសិទ្ធិទិញលក់នេះម្តងណាឡើយ គឺមិនដែលទាល់តែសោះ ហើយច្បាប់ដើមនៃលិខិតផ្ទេរសិទ្ធិទាំងអស់ គឺនៅឱ្យកូនក្តីខ្ញុំបាទ។ ផ្ទុយទៅវិញលោកស្រី [redacted] សុគន្ធារី បែរជាដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌមកលើកូនក្តីខ្ញុំបាទរហូត ដើម្បីគេចវេសអនុវត្តការលក់។ ម្យ៉ាងទៀត លិខិតដែលណាមួយដែលលោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា កូនក្តីខ្ញុំមិនមានសិទ្ធិ[illegible]

Scanned with CamScanner

ទ្រព្យនេះ ប្រសិនបើចរិតនៃការបញ្ចាំ គឺកូនក្តីខ្ញុំបាទមិនមានសិទ្ធិចាត់ចែងនោះទេ។ ជាចុងក្រោយខ្ញុំបាទស្នើសុំចៅក្រមជំនុំជម្រះ ឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទចោទប្រកាន់។

- ក្រោយពីបានស្តាប់អំណាងចម្ហើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណាងចចម្ហើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណាងចម្ហើយបំភ្លឺរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

សំអាងហេតុ

១. ឃល់ឃើញថា ផ្អែកតាមអង្គហេតុ និងភស្តុតាងនានាក្នុងសំណុំរឿង កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុគន្ធារី** អាទស្រី ពិតជាបានខ្ចីចងការប្រាក់ចំនួន ៣.០០០.០០០ (បីលាន) ដុល្លារអាមេរិក ដែលយកការប្រាក់ក្នុងអត្រា ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ ពីជនជាប់ចោទឈ្មោះ [redacted] **អាយវ៉ាន** អាទប្រុស កើតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៤១ និងជនជាប់ចោទឈ្មោះ [redacted] **គីមហុង** អាទស្រី កើតថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៤៦ ដោយឈ្មោះ [redacted] **សុគន្ធារី** អាទស្រី បានកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់លើដីធ្លី និងផ្ទះសម្បែងចំនួនប្រាំកន្លែងមាន៖ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៤/១២ លអបវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៥/១២ លអបវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៦/១២ លអបវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៤/១២ លអបវ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១២ និងលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥៤៥/១២ លអបវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ក្នុងរូបភាពជាការដាក់បញ្ចាំនូវអចលនវត្ថុទាំងប្រាំកន្លែង ដើម្បីជាការធានាសិទ្ធិលើបំណុលជាប្រាក់ដើមចំនួន *៣.០០០.០០០ (បីលាន) ដុល្លារអាមេរិក* និងការប្រាក់ក្នុងអត្រា ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ ប្រាកដមែន។

២. ឃល់ឃើញថា មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានការពារស្នើសុំឈាកចៅក្រមសម្រេច *ផ្តន្ទាទោសជនជាប់ចោទឈ្មោះ* [redacted] *អាយវ៉ាន់* និងប្រពន្ធឈ្មោះ [redacted] *គីមហុង* ទៅតាមបទចោទ ដែលសាលាឧទ្ធរណ៍បញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះនេះ ព្រមទាំងស្នើសុំសំណងរដ្ឋប្បវេណីចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។ ចំពោះសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីនេះ តុលាការនឹងពិនិត្យ ពិចារណា និងសម្រេចដោយស្របតាមច្បាប់។

៣. ឃល់ឃើញថា តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការស្តាប់ចម្លើយសាលនាពេលសវនាការនេះ តំណាងអយ្យការ ស្នើសុំឱ្យចៅក្រមជំនុំជម្រះពិនិត្យមើលលើភស្តុតាង និងសេចក្តីសម្រេចរបស់តុលាការកំពូល ក៏ដូចជាសេចក្តីសម្រេចរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ និងស្នើសុំឱ្យតុលាការសម្រេចទៅតាមច្បាប់។ ចំពោះការប្តឹងសុំរបស់តំណាងអយ្យការនេះ តុលាការនឹងពិនិត្យ ពិចារណា និងសម្រេចដោយស្របតាមច្បាប់។

៤. ឃល់ឃើញថា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ ស្នើសុំចៅក្រមជំនុំជម្រះឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់។ ចំពោះសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនេះ តុលាការនឹងពិនិត្យ ពិចារណា និងសម្រេចដោយស្របតាមច្បាប់។

៥. ឃល់ឃើញថា ផ្អែកតាមលិខិតទទួលប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ រវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទទាំងពីរ ដែលមានភាពស៊ីសង្វាក់គ្នាទៅនឹងការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការទទួលស្គាល់បានថា អង្គហេតុនៃការខ្ចីប្រាក់ចំនួន ៣.000.000 (បីលាន) ដុល្លារអាមេរិក ដោយតម្រូវឱ្យមានការផ្ទេរសិទ្ធិកាន់កាប់លើអចលនវត្ថុចំនួន ៥ (ប្រាំ) កន្លែងនេះ ពិតជាស្ថិតក្រោមរូបភាពនៃការខ្ចីប្រាក់ និងដាក់បញ្ចាំអចលនវត្ថុ ដើម្បីធានាសិទ្ធិលើបំណុល ប្រាកដមែន។ អង្គហេតុនេះ ពុំស្ថិតក្រោមរូបភាពនៃការទិញលក់អចលនវត្ថុ ដូចការអះអាងរបស់ជនជាប់ចោទឡើយ។

៦. ឃល់ឃើញថា កិច្ចសន្យាខ្ចីប្រាក់ចំនួន ៣.000.000 (បីលាន) ដុល្លារអាមេរិក ដោយតម្រូវឱ្យមានការផ្ទេរសិទ្ធិកាន់កាប់លើអចលនវត្ថុចំនួន ៥ (ប្រាំ) កន្លែងនេះ ជាកិច្ចសន្យាបញ្ចាំផ្តាច់ ដែលត្រូវបានហាមឃាត់ដោយមាត្រា ៨២៧ (ការហាមកិច្ចសន្យាបញ្ចាំផ្តាច់) នៃក្រមរដ្ឋប្បវេណី។

៧. ឃល់ឃើញថា កិច្ចសន្យាបញ្ចាំផ្តាច់ ជាកិច្ចសន្យាដែលមានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។ កិច្ចសន្យាប្រភេទនេះ ត្រូវបានចាត់ទុកជាមោឃៈ ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ស្របតាមបញ្ញត្តិមាត្រា៣៥៤ នៃក្រមរដ្ឋប្បវេណី។ ចំពោះកិច្ចសន្យាដែលត្រូវបានចាត់ទុកជាមោឃៈច្បាប់មិនទទួលស្គាល់អានុភាពនៃកិច្ចសន្យានោះទេ ដែលនាំឱ្យគ្មានសិទ្ធិលើបំណុល និងគ្មានកាតព្វកិច្ចណាមួយកើតឡើងដោយកិច្ចសន្យានោះឡើយ។ ដូច្នេះ តុលាការឃល់ឃើញថា ពុំអាចមានស្ថានភាពមិនបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ក្នុងការប្រគល់សងវិញនូវវត្ថុដែលត្រូវបានប្រគល់ឱ្យទៅជនជាប់ចោទ ក្នុងអង្គហេតុនេះឡើយ ដែលបង្ហាញអំពីកង្វះធាតុផ្សំសព្វាធម៌តនៃបទល្មើសរំលោភលើទំនុកចិត្ត តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

៨. ឃល់ឃើញថា តាមការអះអាង និងភស្តុតាងនានាក្នុងសំណុំរឿង អង្គហេតុនេះ ជារឿងក្តីរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិកាន់កាប់លើអចលនវត្ថុពីដើមបណ្តឹងរដ្ឋប្បវេណីទៅជនជាប់ចោទ ដោយគ្មានកាតព្វកិច្ច ដែលមិនបង្កើតជាបទល្មើសរំលោភលើទំនុកចិត្ត តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ឡើយ។

<u>សន្និដ្ឋាន៖</u> តាមសំអាងហេតុខាងលើនេះ តុលាការរកឃើញថា អំពើនោះមិនមែនជាបទល្មើសទេ។ ដូច្នេះ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ ស្របតាមមាត្រា៣៥០ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ហេតុដូច្នេះសម្រេច

ឱ្យជនជាប់ចោទឈ្មោះ [redacted] អាយវ៉ាន់ ភេទប្រុស កើតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៤១ និងជនជាប់ចោទឈ្មោះ [redacted] គីមហុង ភេទស្រី កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៤៦ រួចខ្លួនពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១ ដោយកំពុងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេលដែលច្បាប់បានកំណត់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងឈ្មោះ៖ [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងឈ្មោះ៖ [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner